ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

សំណុំរឿងរដ្ឋប្បវេណី

លេខ ២៥២៨

ចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០២៣

សាលក្រមរដ្ឋប្បវេណី

លេខ ៩១ "ញ៦"

ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០២៤

# សាលក្រម

## តាងនាមប្រជារាស្ត្រខ្មែរ

## សាលាដំបូងរាជធានីភ្នំពេញ

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់

នៅថ្ងៃទី១២ ខែមករា ឆ្នាំ២០២៤

**ចៅក្រមជំនុំជម្រះ**

លោក [redacted] ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ

**ក្រឡាបញ្ជី**

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

**ដើមចោទ÷**

**-ឈ្មោះ** [redacted] **ម៉ារ៉ា** ភេទស្រី កើតថ្ងៃទី០២ ខែកញ្ញា ឆ្នាំ១៩៩៧ ជនជាតិខ្មែរ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ [redacted]

**អ្នកតំណាងដោយអាណត្តិឲ្យដើមចោទ÷**

-លោក [redacted] ជាមេធាវីតំណាងដោយអាណត្តិ ។

**ចុងចម្លើយ ÷**

**១**-ឈ្មោះ [redacted] **វ៉ាន់ដា** ភេទប្រុស កើតថ្ងៃទី១៨ ខែសីហា ឆ្នាំ១៩៨០ ជនជាតិខ្មែរ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ [redacted] ។

**អ្នកតំណាងដោយអាណត្តិឲ្យចុងចម្លើយ÷**

-លោកស្រី [redacted] ជាមេធាវីតំណាងដោយអាណត្តិ ។

### អង្គហេតុ និង ចំណុចវិវាទ

**ក. ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារ**

**១**.លែងលះនឹងឈ្មោះ [redacted] **វ៉ាន់ដា**

**២**.ទាមទារសិទ្ធិអំណាចមេបាលើកូនឈ្មោះ [redacted] **សំរិទ្ធិចក្រា** ភេទប្រុស កើតថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៨

**៣**.ទ្រព្យសម្បត្តិរួមបែងចែកជាពីរចំណែកស្មើគ្នា

**៤**.ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ចុងចម្លើយ ។

**ខ. ដំណើររឿងក្តី និង ចំណុចវិវាទ**

**ខ.១. ការសង្ខេបអំពីរឿងក្តី**

កាលពីអំឡុងឆ្នាំ២០១៧ ដើមចោទ និងចុងចម្លើយបានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា និងបានចុះសំបុត្រអាពាហ៍ពិពាហ៍លេខ **២៧** នៃសៀវភៅអាពាហ៍ពិពាហ៍លេខ ០១/២០១៧ ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១៧ ។ នៅក្នុងទំនាក់ទំនងអាពាហ៍ពិពាហ៍...

Scanned with CamScanner

ដើមចោទ និងចុងចម្លើយមានបង្កើតបានកូនម្នាក់ឈ្មោះ[redacted]សំរិទ្ធិចក្រា ភេទប្រុស កើតថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៨ ហើយ ទំនាក់ទំនងអាពាហ៍ពិពាហ៍នេះ ដើមចោទ និងចុងចម្លើយបានរស់នៅជាមួយគ្នាមានភាពល្អប្រសើរ រហូតដល់មួយរយៈពេល ចុងក្រោយដើមចោទ និង ចុងចម្លើយតែងតែទាស់សម្តីគ្នា រស់នៅមិនចុះសម្រុងនឹងគ្នា ។ រហូតដល់ឆ្នាំ២០២១ ដើមចោទ និង ចុងចម្លើយនៅតែមិនអាចសម្រុះសម្រួលគ្នា និងជជែកចរចាដើម្បីរួមរួសជាមួយគ្នាទៀតបាន ហើយការរស់នៅទៀតសោតក្នុង យៈពេល ២,៣ឆ្នាំចុងក្រោយ គឺភាគីទាំងពីររស់នៅឆ្ងាយពីគ្នា ជាហេតុធ្វើឱ្យភាគីទាំងពីរអស់មនោសញ្ចេតនាជាប្តីប្រពន្ធនឹងគ្នា បន្តទៅទៀត ។

**១.២. អង្គហេតុដែលគ្មានវិវាទ÷**

១.២.១. ដើមចោទ និងចុងចម្លើយពិតជាបានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា និងដោយបានចុះសំបុត្រអាពាហ៍ពិពាហ៍លេខ៖ ២៧ នៃសៀវភៅអាពាហ៍ពិពាហ៍លេខ៖ ០១/២០១៧ ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១៧ ។

១.២.២. នៅក្នុងអំឡុងពេលរស់នៅជាមួយគ្នា ដើមចោទ និងចុងចម្លើយមានកូនម្នាក់ឈ្មោះ [redacted]**សំរិទ្ធិចក្រា** ភេទប្រុស កើតថ្ងៃទី២៥ ខែតុលា ឆ្នាំ២០២៣ ។ ដើមចោទ និងចុងចម្លើយ បានពិភាក្សាគ្នារួចហើយអំពីការកំណត់អ្នកមានអំណាចមេបា ដោយភាគីបានព្រមព្រៀងគ្នាកំណត់ឱ្យដើមចោទ ជាអ្នកមានអំណាចមេបាលើកូន និងរួមគ្នាផ្គត់ផ្គង់អាហារកិច្ចសម្រាប់ចិញ្ចឹមកូន ។

**១.៣. ចំណុចវិវាទ** ÷ តើទំនាក់ទំនងអាពាហ៍ពិពាហ៍រវាងគូភាគី ពិតជាមិនអាចបដិទានឡើងមែនដែរ ឬទេ?

**១.៤. ការអះអាងរបស់ភាគី**

**១.៤.១.** ការអះអាងរបស់ដើមចោទដោយមូលហេតុដូចខាងក្រោម ៖

**អំពីការទាមទារចំណុចទី១៖** ខ្លួន និងចុងចម្លើយបានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាត្រឹមត្រូវតាមច្បាប់កាលពីឆ្នាំ២០១៧ និងបានចុះសំបុត្រអាពាហ៍ពិពាហ៍លេខ **២៧** ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១៧ ។ កាលដើមឡើយទំនាក់ទំនាក់ទំនងរវាងភាគីទាំងពីរមានភាពល្អប្រសើរ រហូតមកដល់មួយរយៈចុងក្រោយនេះតែមានការទាស់ទែងរស់នៅមិនចុះសម្រុងនឹងគ្នា ព្រម ទាំងមានការខ្វែងគំនិតគ្នាដែលនាំឱ្យភាគីទាំងពីរអស់មនោសញ្ចេតនាជាប្តីប្រពន្ធនឹងគ្នា ។ លើសពីនេះភាគីទាំងពីរបានរស់នៅឆ្ងាយពីគ្នាដែលនាំឱ្យមិនអាចចរចារកចំណុចមួយដើម្បីរួមរស់ជាមួយគ្នាវិញបាន ។

**អំពីការទាមទារចំណុចទី២៖** នៅក្នុងចំណងអាពាហ៍ពិពាហ៍ ខ្លួន និងចុងចម្លើយមានកូនចំនួនម្នាក់ឈ្មោះ [redacted]**សំរិទ្ធិចក្រា** ភេទប្រុស កើតថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៨ ។ ហើយខ្លួនសុំទាមទារសិទ្ធិអំណាចមេបាលើកូនឈ្មោះ[redacted] **សំរិទ្ធិចក្រា** ដោយហេតុថា កូនប្រុសតាំងពីកើតមកគឺរស់នៅជាមួយខ្លួន ដែលខ្លួនជាអ្នកមើលថែរក្សាបីបាច់ បើសិនកូនទៅរស់នៅជាមួយចុងចម្លើយ ចុងចម្លើយមិនអាចផ្តល់ភាពកក់ក្តៅដូចខ្លួននោះទេ ហើយខ្លួនក៏មានមុខរបរបើកក្លិបហាត់ប្រាណផ្ទាល់ខ្លួនផងដែរ ។

**អំពីការទាមទារចំណុចទី៣៖** ខ្លួនស្នើសុំឱ្យបែងចែកទ្រព្យសម្បត្តិជាពីរស្មើគ្នា ដោយហេតុថាក្នុងអំឡុងពេលមានចំណងអាពាហ៍ពិពាហ៍ ខ្លួនមិនបានដឹងថាចុងចម្លើយមានទ្រព្យសម្បត្តិអ្វីខ្លះនោះទេ ព្រោះកន្លងមកមិនធ្លាប់ដាក់ប្រាស់ចំណូលដែលរកបានបញ្ចូលគ្នានោះឡើយ ។

**១.៤.២.** ការអះអាងរបស់ចុងចម្លើយ ៖

**អំពីការទាមទារចំណុចទី១៖** ចំពោះការទាមទារលែងលះរបស់ដើមចោទ ខ្លួនទទួលស្គាល់ថាពិតជាមានផ្ទុតគំនិតខ្វែងគ្នា និងមិនអាចរកចំណុចចរចារស់នៅជាមួយគ្នាវិញបាន ដែលជាហេតុធ្វើឱ្យភាគីទាំងពីរអស់មនោសញ្ចេតនានឹងគ្នាជាប្តីប្រពន្ធ ។

**អំពីការទាមទារចំណុចទី២៖** ចំពោះកូនប្រុសឈ្មោះ[redacted]**សំរិទ្ធិចក្រា** ភេទប្រុស កើតថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៨ ខ្លួនឯកភាពចំពោះការប្រគល់សិទ្ធិអ្នកមានអំណាចមេបា ឱ្យទៅដើមចោទដោយហេតុថាកូននៅតូច និងបានរស់នៅជាមួយដើមចោទយូរមកហើយ ហើយខ្លួនស្នើសុំឱ្យដើមចោទរក្សានាមត្រកូល និងនាមខ្លួនរបស់កូនទុកដដែល ។ ចំពោះអាហារកិច្ចរបស់កូន

ខ្លួនសូមឱ្យដើមចោទបង្កើតគណនីធនាគារមួយរួមគ្នា និងសូមចេញបង់ថ្លៃសាលារៀនរបស់កូន ព្រមទាំងផ្តល់ប្រាក់ឧបត្ថម្ភឱ្យដើមចោទចំនួន **២០០ (ពីររយ)** ដុល្លារអាមេរិក ក្នុង **០១ (មួយ) ខែ** សម្រាប់ផ្គត់ផ្គង់ជីវភាពកូន ។

**អំពីការទាមទារចំណុចទី៣៖** ចំពោះទ្រព្យសម្បត្តិរួមរវាងដើមចោទ និងខ្លួន គឺមិនមាននោះឡើយ ប៉ុន្តែមានតែបំណុល។

-មេធាវី [redacted] អ្នកតំណាងដោយអាណត្តិឱ្យចុងចម្លើយ បានធ្វើសេចក្តីថ្លែងការណ៍៖ ចំពោះការជួបប្រាស្រ័យទាក់ទងរវាងចុងចម្លើយ និងកូនឈ្មោះ [redacted] សំរិទ្ធចក្រា ស្នើសុំឱ្យចុងចម្លើយអាចជួបប្រាស្រ័យទាក់ទងក្នុងលក្ខខណ្ឌសមរម្យមួយ ហើយស្នើសុំប្រាក់ប្រដាប់ក្តីតុលាការជាបន្ទុករបស់ដើមចោទ។

**ឯកសារភស្តុតាង**

**១.** សំបុត្រអាពាហ៍ពិពាហ៍លេខ **២៧** នៃសៀវភៅអាពាហ៍ពិពាហ៍លេខ **០១/២០១៧** ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១៨ រវាងឈ្មោះ [redacted] **ភាំងដា** និងឈ្មោះ [redacted] **ម៉ារ៉ា** ចេញដោយមន្ត្រីអត្រានុកូលដ្ឋានសង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ។

២. សំបុត្រកំណើតលេខ **៥៩** នៃសៀវភៅកំណើតលេខ **០២/២០១៨** ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១៨ របស់ឈ្មោះ [redacted] **សំរិទ្ធចក្រា** ភេទប្រុស កើតថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៨ ចេញដោយមន្ត្រីអត្រានុកូលដ្ឋានសង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ។

**សំអាងហេតុ**

**ក្រោយពីបានទាញហេតុផល និងពិចារណាលើភស្តុតាងក្នុងសំណុំរឿង តុលាការវិនិច្ឆ័យសេចក្តីដូចតទៅ៖**

**១.** តាមពាក្យបណ្តឹង ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២៣ របស់ដើមចោទ មានលក្ខណៈត្រឹមត្រូវតាមច្បាប់ ហេតុដូច្នេះសាលាដំបូងរាជធានីភ្នំពេញមានសមត្ថកិច្ច ដើម្បីវិនិច្ឆ័យស្របច្បាប់នូវពាក្យបណ្តឹង ហើយចេញសាលក្រមបានតាមមាត្រា **៧៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី** និងមាត្រា៣ **នៃច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល** ។

**២.** ផ្អែកតាមសំបុត្រអាពាហ៍ពិពាហ៍លេខ ២៧ នៃសៀវភៅអាពាហ៍ពិពាហ៍លេខ **០១/២០១៧** ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១៨ ចេញដោយមន្ត្រីអត្រានុកូលដ្ឋានសង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ បង្ហាញឱ្យឃើញថាអាពាហ៍ពិពាហ៍របស់ដើមចោទ និងចុងចម្លើយ មានអានុភាពស្របតាមបញ្ញត្តិមាត្រា **៩៥៥ នៃក្រមរដ្ឋប្បវេណី** ។

**៣.** ផ្អែកតាមសំបុត្រកំណើតលេខ**៥៩** នៃសៀវភៅកំណើតលេខ **០២/២០១៨** ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១៨ របស់ឈ្មោះ [redacted] **សំរិទ្ធចក្រា** ចេញដោយមន្ត្រីអត្រានុកូលដ្ឋានសង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ បង្ហាញឱ្យឃើញថានៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ដើមចោទ និងចុងចម្លើយ មានកូនចំនួន ១ (មួយ) នាក់ពិតប្រាកដមែន ។ ដោយហេតុថាកូនរបស់ដើមចោទ និងចុងចម្លើយជាអនីតិជន ដូច្នេះក្នុងករណីដែលតុលាការសម្រេចឱ្យភាគីទាំងពីរលែងលះគ្នា គប្បីតុលាការពិចារណាអំពីអ្នកមានអំណាចមេបាលើកូននេះស្របតាមបញ្ញត្តិនៃមាត្រា **១០៣៧ នៃក្រមរដ្ឋប្បវេណី** ។

**៤. ការវិនិច្ឆ័យចំពោះការទាមទារចំណុចទី ១**

ដើមចោទធ្វើសេចក្តីថ្លែងការណ៍ថា ខ្លួនបានរៀបអាពាហ៍ពិពាហ៍ជាមួយចុងចម្លើយដោយបានចុះសំបុត្រអាពាហ៍ត្រឹមត្រូវតាមច្បាប់ ។ ដើមចោទស្នើសុំលែងលះពីចុងចម្លើយដោយហេតុថាមួយរយៈពេលចុងក្រោយទំនាក់ទំនងរវាងដើមចោទ និងចុងចម្លើយហាក់មិនចុះសម្រុងនឹងគ្នា និងតែងទាស់ទែងគ្នា ស្របពេលដែលភាគីទាំងពីរបានរស់នៅឆ្ងាយពីគ្នា ដែលជាហេតុនាំមានការខ្វែងគំនិតគ្នា ធ្វើឱ្យភាគីទាំងពីរអស់មនោសញ្ចេតនាជាប្តីប្រពន្ធបាន ។តុលាការពិនិត្យឃើញ ក្នុងការរួមរស់ជាមួយគ្នាជាប្តីប្រពន្ធរបស់គូភាគី ក្នុងរយៈកាលប្រមាណ ៣ឆ្នាំចុងក្រោយនេះ មានភាពរកាំរកុះច្រើន ដោយបណ្តាលឱ្យមានជម្លោះជាមួយគ្នាជាញឹកញាប់ និងឈានដល់ការបែកលំនៅគ្នា។ ឆ្លងតាមការទាញហេតុផលដោយផ្ទាល់មាត់ តុលាការពិនិត្យឃើញថា វិវាទរវាងគូភាគី ដែលបានធ្លាប់សម្រុះសម្រួលគ្នាជាច្រើនលើនៅក្រៅតុលាការ និងការព្យាយាមផ្សះផ្សារក្នុងនីតិវិធីតុលាការ នៅតែមិនអាចឱ្យគូភាគីយល់ព្រមជានាគ្នាវិញឡើយ។ ជាលទ្ធផលនៃការទាញហេតុផលដោយផ្ទាល់មាត់ គូភាគីបានបង្ហាញឆន្ទៈថា

Scanned with CamScanner

ពួកខ្លួនមានទស្សនៈនៃការយល់ឃើញខុសឆ្ងាយពីគ្នាខ្លាំង មិនអាចរួមរស់ជាមួយគ្នាជាប្តីប្រពន្ធប្រកបដោយសុភមង្គលឡើយ និង សុំឱ្យតុលាការអនុញ្ញាតឱ្យបានលែងលះគ្នា។ ហេតុនេះគប្បីតុលាការពិចារណា និងសម្រេចឱ្យដើមចោទលែងលះពីចុងចម្លើយ តាមច្បាប់ ស្របតាមបញ្ញត្តិនៃមាត្រា **៩៧៨ ចំណុច ង នៃក្រមរដ្ឋប្បវេណី** ។

**៥. ការវិនិច្ឆ័យចំពោះការទាមទារចំណុចទី ២**

**៥.១.** ដើមចោទបានធ្វើសេចក្តីថ្លែងការណ៍ ក្នុងអំឡុងអាពាហ៍ពិពាហ៍រវាងដើមចោទ និងចុងចម្លើយ ភាគីទាំងពីរមាន កូនចំនួន ០១ (មួយ) នាក់ឈ្មោះ [redacted] **សំរិទ្ធិចក្រា** ភេទប្រុស កើតថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៨ ។ ហើយដើមចោទបានស្នើសុំ អ្នកមានអំណាចមេបាលើកូន ដោយហេតុថាកូននៅជាមួយនឹងខ្លួនតាំងពីកើតមក ។ ចុងចម្លើយក៏បានឯកភាពក្នុងការប្រគល់ សិទ្ធិអ្នកមានអំណាចមេបាលើកូនឱ្យទៅដើមចោទ តុលាការយល់ឃើញថា គូភាគីបានពិភាក្សាគ្នាអំពីការកំណត់អ្នកមាន អំណាចមេបា ហេតុដូច្នេះគប្បីតុលាការសម្រេចតាមការពិភាក្សារបស់ភាគីស្របតាមបញ្ញត្តិមាត្រា **១០៣៧ កថាខណ្ឌ១ នៃ ក្រមរដ្ឋប្បវេណី**។

**៥.២.** ផ្អែកតាមការទាញហេតុផលដោយផ្ទាល់មាត់ ភាគីដើមចោទ និងចុងចម្លើយយល់ព្រមក្នុងការផ្តល់អាហារកិច្ច ដល់កូននិងសិទ្ធិចូលជួបប្រាស្រ័យទាក់ទងជាមួយកូនឈ្មោះ [redacted] **សំរិទ្ធិចក្រា** គ្រប់ពេលវេលា។ ចុងចម្លើយបានព្រមព្រៀងក្នុង ការរ៉ាប់រងបង់ថ្លៃសាលារៀនរបស់កូន និងរួមគ្នាដាក់ប្រាក់ម្នាក់ៗចំនួន **២០០ (ពីររយ)** ដុល្លារអាមេរិក ក្នុង **០១(មួយ)** ខែ សម្រាប់ផ្គត់ផ្គង់ជីវភាពកូន រហូតដល់កូនចូលវ័យនីតិភាព ។ ផ្អែកតាមការទាញហេតុផលដោយផ្ទាល់មាត់ខាងលើ តុលាការ យល់ឃើញថាគូភាគីបានពិភាក្សាឯកភាពគ្នាអំពីករណីយកិច្ចទទួលបន្ទុកសោហ៊ុយចាំបាច់គ្រប់គ្រងថែរក្សាកូន គប្បីតុលាការ សម្រេច តាមការពិភាក្សារបស់គូភាគីស្របតាមបញ្ញត្តិនៃមាត្រា**១០៤០ កថាខណ្ឌ១ និងកថាខណ្ឌ២ នៃក្រមរដ្ឋប្បវេណី** ។ ដោយតុលាការបានពិចារណាប្រគល់អំណាចមេបាលើកូនទៅឱ្យដើមចោទ ហេតុនេះ តុលាការត្រូវបង្គាប់ឱ្យចុងចម្លើយបង់ សោហ៊ុយចាំបាច់ដើម្បីចិញ្ចឹមថែរក្សាកូនទៅឱ្យដើមចោទ។

**៥.៣.** ចំពោះការរក្សានាមត្រកូល និងនាមខ្លួនរបស់កូនដែលចុងចម្លើយបានធ្វើការទាមទារ តុលាការពិនិត្យឃើញថា វាមិនមែនជាចំណុចដែលតុលាការត្រូវសម្រេចក្នុងនីតិវិធីនៃការលែងលះនេះទេ ហេតុនេះតុលាការសម្រេចច្រានចោល។

**៥.៤.** ផ្អែកតាម**មាត្រា១០៤០ នៃក្រមរដ្ឋប្បវេណី** ឪពុក ឬម្តាយ ដែលពុំមានអំណាចមេបា ក្រោយពេលលែងលះគ្នា មានសិទ្ធិចូលជួបនិងប្រាស្រ័យទាក់ទងជាមួយកូន និងមានករណីយកិច្ចទទួលបន្ទុកលើសោហ៊ុយដែលចាំបាច់ដើម្បីគ្រប់គ្រង ថែរក្សាកូន ហេតុនេះគូភាគីត្រូវយកចិត្តទុកដាក់ និងសម្របសម្រួលចំពោះគ្នាទៅវិញទៅមកក្នុងការអនុវត្តសិទ្ធិនិងករណីយកិច្ច នេះឱ្យមានប្រសិទ្ធភាព។

**៦. ការវិនិច្ឆ័យអំពីការទាមទារចំណុចទី ៣**

ដើមចោទបានធ្វើសេចក្តីថ្លែងការណ៍ដោយស្នើសុំធ្វើការបែងចែកទ្រព្យសម្បត្តិជាពីរចំណែកស្មើគ្នាដោយមូលហេតុថា ក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ខ្លួន មិនដឹងថាចុងចម្លើយមានទ្រព្យសម្បត្តិអ្វីខ្លះនៅឡើយ ហើយក៏មិនធ្លាប់បានដាក់ប្រាក់ ចំណូលជាមួយគ្នានោះដែរ ។ ចុងចម្លើយបានធ្វើសេចក្តីថ្លែងការណ៍តបថានៅក្នុងចំណងអាពាហ៍ពិពាហ៍ខ្លួនមិនមានទ្រព្យ សម្បត្តិណាមួយរួមជាមួយដើមចោទនោះឡើយ គឺមានតែបំណុល ។ ផ្អែកតាមការអះអាង និងពិនិត្យទៅលើភស្តុតាងដែល មានក្នុងសំណុំរឿងបង្ហាញឱ្យឃើញថា ក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ដើមចោទ និងចុងចម្លើយមិនមានទ្រព្យសម្បត្តិណាមួយ រួមគ្នានោះឡើយ ហេតុនេះតុលាការមិនធ្វើការពិចារណា និងសម្រេចទៅលើការបែងចែកទ្រព្យសម្បត្តិស្របតាមបញ្ញត្តិនៃ មាត្រា **៩៨០ នៃក្រមរដ្ឋប្បវេណី** នោះទេ ។ទូ៧

Scanned with CamScanner

**៧. ការវិនិច្ឆ័យចំពោះការទាមទារចំណុចទី ៤**

ចំពោះការសម្រេចអំពីការទទួលបន្ទុកប្រាក់ប្រដាប់ក្ដីនៅក្នុងរឿងក្ដីនេះ   តុលាការបានធ្វើការវិនិច្ឆ័យទទួលស្គាល់ការទាមទាររបស់ដើមចោទ ដូច្នេះគប្បីឱ្យភាគីចុងចម្លើយទទួលបន្ទុកលើប្រាក់ប្រដាប់ក្ដីតុលាការ ស្របតាមបញ្ញត្តិមាត្រា ៦៤ នៃ**ក្រមនីតិវិធីរដ្ឋប្បវេណី** ។

## សេចក្ដីសម្រេចបញ្ចប់

១. ឱ្យដើមចោទឈ្មោះ [redacted] **ម៉ារ៉ា** ភេទស្រី កើតថ្ងៃទី០២ ខែកញ្ញា ឆ្នាំ១៩៩៧ និងចុងចម្លើយឈ្មោះ [redacted] **រ៉ាន់ដា** ភេទប្រុស កើតថ្ងៃទី១៨ ខែកក្កដា ឆ្នាំ១៩៨០ **លែងលះគ្នា** ។

២. កំណត់ថាដើមចោទឈ្មោះ [redacted] **ម៉ារ៉ា** ភេទស្រី កើតថ្ងៃទី០២ ខែកញ្ញា ឆ្នាំ១៩៩៧ ជាអ្នកមានអំណាចមេបាលើកូនឈ្មោះ [redacted] **ស៊ំវិទ្ធចក្រា** ភេទប្រុស កើតថ្ងៃ២៥ ខែតុលា ឆ្នាំ២០១៨ ដែលជាកូនរវាងដើមចោទ និងចុងចម្លើយ ។

**២.១.** ដើមចោទត្រូវអនុញ្ញាតឱ្យចុងចម្លើយមានសិទ្ធិចូលជួបប្រាស្រ័យទាក់ទងកូនឈ្មោះ [redacted] **ស៊ំវិទ្ធចក្រា** ។

**២.២.** បង្គាប់ឱ្យចុងចម្លើយឈ្មោះ [redacted] **រ៉ាន់ដា** រ៉ាប់រងថ្លៃសាលារៀនកូនឈ្មោះ [redacted] **ស៊ំវិទ្ធចក្រា** រហូតដល់កូនបានដល់វ័យនីតិភាព ។

**២.៣.** បង្គាប់ឱ្យចុងម្លើយបង់សោហ៊ុយចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាកូនចំនួន **២០០ (ពីររយ)** ដុល្លារអាមេរិក ក្នុង **០១ (មួយ) ខែ** ទៅឱ្យដើមចោទ រហូតដល់កូនបានដល់វ័យនីតិភាព។

៣. ច្រានចោលការទាមទារបែងចែកទ្រព្យសម្បត្តិរួម ។

៤. ច្រានចោលការស្នើសុំរបស់ចុងចម្លើយលើចំណុចទី៣ នៃសេចក្ដីថ្លែងការណ៍ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២៣ ។

**៥.** ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ចុងចម្លើយ ។

សាលក្រមនេះត្រូវបានទាញហេតុផលជាអសាធារណៈ នាថ្ងៃទី១២ ខែមករា ឆ្នាំ២០២៤ និងប្រកាសជាសាធារណៈនាថ្ងៃទី១៨ ខែមករា ឆ្នាំ២០២៤ ។

គូភាគីមានសិទ្ធិសិទ្ធិប្ដឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

**ចៅក្រម**

ហត្ថលេខា និងត្រា [redacted]

---

បានចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃសុក្រ ៨ កើត ខែបុស្ស ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧

រាជធានីភ្នំពេញ, ថ្ងៃទី១៨ ខែមករា ឆ្នាំ២០២៤

**ក្រឡាបញ្ជី**

[redacted]

បានឃើញ

**ចៅក្រម**

[redacted]